# សង្ខេបសំរាប់ គោលនយោបាយ

CDRI គឺជាវិទ្យាស្ថានកម្ពុជា ឯករាជ្យឈានមុខគេ
សំរាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

20th ANNIVERSARY CDRI 1990-2010

ឆ្នាំ2010 លេខ 06


## ការដឹកនាំនៅថ្នាក់ភូមិ ឃុំ នៅប្រទេសកម្ពុជា៖ លទ្ធផលស្រាវជ្រាវ និង គោលនយោបាយពាក់ព័ន្ធ[១]


ដោយលោកស្រី ធន់ វិមាលា


អត្ថបទសង្ខេបនេះ រៀបរាប់ពីលទ្ធផលរកឃើញចំបងៗនៃការសិក្សាពីការដឹកនាំនៅថ្នាក់ភូមិ ឃុំ ក្នុងឃុំចំនួនបី និងបង្ហាញត្រួសៗពីបញ្ហាប្រឈម និងឱកាសនានា ដែលពាក់ព័ន្ធនឹងការដឹកនាំនេះ ជាពិសេសការផ្លាស់ប្តូរនៅក្នុងតួនាទីមួយចំនួនរបស់ថ្នាក់ដឹកនាំ និងការរំពឹងរបស់ប្រជាជនទៅលើថ្នាក់ដឹកនាំដែលជាលទ្ធផលនៃការធ្វើវិមជ្ឈការ នៅក្រោមឥទ្ធិពលប្រព័ន្ធខ្សែខ្នង ។ អត្ថបទនេះ ផ្តោតជាពិសេសលើតួនាទីខុសៗគ្នារបស់អ្នកដឹកនាំនៅថ្នាក់មូលដ្ឋាន ក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងរដ្ឋ និងប្រជាជន ។ អត្ថបទនេះ ក៏ជួយផ្តល់ជាគោលនយោបាយពាក់ព័ន្ធមួយចំនួន សំរាប់ឲ្យរដ្ឋាភិបាលថ្នាក់មជ្ឈិម អាជ្ញាធរមូលដ្ឋាន និងអង្គការសង្គមស៊ីវិល ចូលរួមចំណែកក្នុងការលើកស្ទួយដំណើរការវិមជ្ឈការ ឲ្យកាន់តែប្រសើរឡើង ។

ការសិក្សាពីការដឹកនាំនៅថ្នាក់ភូមិ ឃុំ មានគោលដៅ (១) កំណត់នូវប្រភេទផ្សេងៗនៃថ្នាក់ដឹកនាំ នៅតាមភូមិឃុំ ដោយផ្អែកលើចំណាប់អារម្មណ៍របស់អ្នកភូមិ (២) កំណត់ពីលក្ខណៈផ្សេងៗ ដែលផ្តល់ភាពពេញសិទ្ធិដល់ថ្នាក់ដឹកនាំ និង (៣) ស្វែងរកមើលថា តើថ្នាក់ដឹកនាំទាំងនោះបានជួយធ្វើឲ្យរដ្ឋ និងប្រជាជន ខិតមកជិតគ្នាដែរឬទេ ហើយនេះជាវត្ថុបំណងដ៏សំខាន់មួយនៃវិមជ្ឈការ ។ ការសិក្សា ប្រើប្រាស់វិធីសាស្រ្តបែបគុណភាពជាចំបង ដោយមុនដំបូង បានធ្វើសម្ភាសន៍ជាមួយអ្នកភូមិ ដើម្បីកំណត់រកថ្នាក់ដឹកនាំ ហើយបន្ទាប់មកទើបធ្វើសម្ភាសន៍ស៊ីជម្រៅជាមួយអ្នកដឹកនាំទាំងនោះ ។ ការសិក្សានេះក៏មានក្រុមអ្នកស្រាវជ្រាវ ចុះសង្កេតសកម្មភាពរបស់អ្នកដឹកនាំផ្សេងៗផងដែរ ។

### ការពិនិត្យជាទូទៅ

កំណែទម្រង់វិមជ្ឈការ បានចាប់អនុវត្តតាំងពីជាង ៧ឆ្នាំមុន ដោយអនុញ្ញាតឲ្យប្រជាជន មានសិទ្ធិបោះឆ្នោតជ្រើសរើសតំណាងឃុំរបស់ខ្លួន ។ ការសិក្សានេះ បានរកឃើញក្រុមអ្នកតំណាងជាច្រើនក្នុងការដឹកនាំនៅមូលដ្ឋាន ហើយក្នុងនេះ ចំនួនសមាជិកក្រុមប្រឹក្សាឃុំ និងគណៈកម្មការភូមិ ក៏កើនឡើងដែរ ។ ដោយឡែក ថ្នាក់ដឹកនាំមូលដ្ឋានជាស្រ្តីមានកាន់តែច្រើននាក់ ដោយសារមានឱកាស និងមុខតំណែងកាន់តែច្រើន បានបើកចំហសំរាប់ពួកគាត់ ។ យើងក៏សង្កេតឃើញដែរ នូវកំណើនថ្នាក់ដឹកនាំដែលមានបទពិសោធន៍ និងទឹកចិត្តធ្វើការងារខ្ពស់ ដែលបានជួយរក្សាស្ថិរភាពសហគមន៍ និងការដឹកនាំនៅថ្នាក់មូលដ្ឋាន ។ ប្រជាជនកាន់តែទទួលស្គាល់ថ្នាក់ដឹកនាំទាំងនេះពីព្រោះពួកគាត់មានបទពិសោធន៍ច្រើន មានឆន្ទៈ ហើយអាចប្រើប្រាស់ចំណេះដឹងរបស់ខ្លួនអំពីតំបន់នោះ ដើម្បីដោះស្រាយបញ្ហាផ្សេងៗក្នុងមូលដ្ឋានឲ្យមានប្រសិទ្ធភាព ។ ថ្នាក់ដឹកនាំនៅមូលដ្ឋានខ្លះ អនុវត្តការងារបានល្អណាស់ក្នុងការភ្ជាប់ទំនាក់ទំនងរវាងរដ្ឋ និងប្រជាជន ។ ថ្នាក់ដឹកនាំនៅមូលដ្ឋានអាចកៀងគរធនធានប្រកបដោយប្រសិទ្ធភាព ធ្វើឲ្យរដ្ឋាភិបាល និងមន្រ្តីរាជការ យកចិត្តទុកដាក់ស្តាប់មតិរបស់ពួកគេ ។ ក្នុងចំណុចនេះ វិមជ្ឈការដំណើរការបានល្អ ។

ទោះមានលទ្ធផលល្អដូចខាងលើក្តី ក៏នៅមានបញ្ហាច្រើនទៀតដែលត្រូវដោះស្រាយ ។ ការចាត់ចែងតាមបែបឋានានុក្រមដែលនៅសេសសល់ និងឥទ្ធិពលប្រព័ន្ធខ្សែខ្នង បានកាត់បន្ថយប្រសិទ្ធភាព និងល្បឿននៃកំណែទម្រង់នេះ ។ ការសិក្សានេះបានវែកញែកជាពិសេស ពីការងារនយោបាយគណបក្សដែលប្រើប្រាស់បណ្តាញខ្សែខ្នង ជាមធ្យោបាយដើម្បីពង្រឹងអំណាច ហើយជាទូទៅបានបង្កឧបសគ្គដល់ការធ្វើវិមជ្ឈការ ។

ជារឿយៗ មានការអះអាង និងសន្និដ្ឋានថា ការដែលការងារនយោបាយគណបក្ស អាចប្រព្រឹត្តទៅដោយគ្របដណ្តប់លើការងារផ្លូវការរបស់រដ្ឋអាចសំរេចទៅបាន ដោយសារមិនមានស្ថាប័ន ឬដោយសារស្ថាប័នអន់ខ្សោយ ហើយសង្គមស៊ីវិលក៏ទន់ខ្សោយ ។ បញ្ហានេះ នាំឲ្យអាជ្ញាធរមូលដ្ឋានខ្វះខាតសិទ្ធិអំណាច ហើយសិទ្ធិអំណាចជាក់ស្តែងស្ថិតក្នុងដៃពួកអភិជនមួយចំនួនដែលមានឥទ្ធិពលច្រើន ទាំងលើការងារនយោបាយនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ។

### លទ្ធផលពីករណីសិក្សា

#### ១.ថ្នាក់ដឹកនាំនៅមូលដ្ឋានភាគច្រើន នៅតែមិនទាន់ផ្លាស់ប្តូរ

ការសិក្សារកឃើញថា អ្នកដឹកនាំរដ្ឋបាលនៅតាមមូលដ្ឋានសឹងតែជាអ្នកដដែលៗ ហើយភាគច្រើនមានអាយុលើសពី ៤៩ឆ្នាំ

-----

[១] សង្ខេបគោលនយោបាយនេះ ផ្អែកលើឯកសារពិភាក្សាលេខ ៤២ របស់វិទ្យាស្ថាន CDRI ស្តីពីការដឹកនាំនៅថ្នាក់ភូមិឃុំនៅប្រទេសកម្ពុជា៖ ករណីសិក្សានៅ ៣ឃុំ ក្នុង ៣ខេត្ត របស់លោកស្រី ធន់ វិមាលា លោក អ៊ូ ស៊ីវហួច លោកស្រី អេង នេត្រា និង លោកស្រី លី តឹម (២០០៩) ។

និងមានតួនាទីក្នុងការដឹកនាំតាំងពីឆ្នាំ១៩៧៩ ឬមុននោះទៀត ។ ភាពពេញនិយមរបស់ពួកគាត់ គឺស្ថិតនៅលើលក្ខណៈជាប្រពៃណី ដែលប្រជាជនទទួលស្គាល់ពួកគាត់ ដោយសារគាត់ជាចាស់ទុំ ឬក៏ជាអ្នកដឹកនាំពីមុន ។ ករណីសិក្សានេះបង្ហាញថា អ្នកដឹកនាំដែលមានលក្ខណៈប្រពៃណី និងការធ្លាប់ធ្វើជាអ្នកដឹកនាំពីអតីតកាល ទំនងជាឱកាសចំបងឲ្យជននោះជាប់ឈ្មោះជាបេក្ខជន និងជាប់ឆ្នោតជាអ្នកដឹកនាំ ។ រឿងនេះបង្កការលំបាកដល់បេក្ខជនថ្មីៗ ទោះបីពួកគេមានសមត្ថភាពការងារល្អក្តី ។ បេក្ខជនថ្មីៗ ត្រូវកសាងទំនាក់ទំនងជាមួយគណបក្សនយោបាយ ឬអ្នកមានអំណាច ដើម្បីចូលក្នុងពិភពនយោបាយ និងឈរឈ្មោះសំរាប់ការបោះឆ្នោត ។

វិមជ្ឈការ បានធ្វើការផ្លាស់ប្តូរនូវការទទួលខុសត្រូវ និងតួនាទីរបស់ថ្នាក់ដឹកនាំឃុំ ប៉ុន្តែសមត្ថភាព និងសកម្មភាពរបស់ពួកគាត់ សឹងតែគ្មានការផ្លាស់ប្តូរ ។ បញ្ហានេះ បង្កឧបសគ្គដល់ការបំពេញតួនាទីថ្មីដើម្បីដោះស្រាយបញ្ហាផ្សេងៗ និងបំពេញតម្រូវការដែលកើនឡើងពីប្រជាជន ។

## ២. ថ្នាក់ដឹកនាំមូលដ្ឋានខ្វះខាតស្វ័យភាព និងឯករាជភាព

ដោយសារវិសហមជ្ឈការ បានដាក់អនុវត្តយឺតជាងវិមជ្ឈការ ថ្នាក់ដឹកនាំឃុំមិនបានទទួលសិទ្ធិអំណាច និងធនធានពេញលេញទេ ។ ម៉្យាងទៀត មូលនិធិប្រចាំឆ្នាំរបស់ពួកគេដែលទទួលបានពីមូលនិធិឃុំសង្កាត់ (CSF) មានចំនួនតិចតួច មិនអាចឲ្យពួកគេអនុវត្តការងារបានដោយឯករាជ្យឡើយ ។

ថ្នាក់ដឹកនាំឃុំ ត្រូវពឹងលើហិរញ្ញប្បទានពីគណបក្ស ដើម្បីអនុវត្តគម្រោងអភិវឌ្ឍន៍នានារបស់ខ្លួន ព្រោះ CSF មានគ្រប់គ្រាន់សំរាប់តែការងាររដ្ឋបាលប៉ុណ្ណោះ ។[២] គណបក្សនយោបាយ ក៏ដូចជាប្រជាជន រំពឹងថាក្រុមប្រឹក្សាឃុំនឹងនាំមកនូវគម្រោងអភិវឌ្ឍន៍ ជាពិសេសផ្នែកហេដ្ឋារចនាសម្ព័ន្ធ ។ សមិទ្ធផលទាំងនេះ រួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើនភាពពេញសិទ្ធិរបស់អ្នកដឹកនាំ ។ ដូច្នេះ ពួកគេត្រូវពឹងផ្អែកលើការគាំទ្រ និងមូលនិធិក្រៅផ្លូវការ ដែលបានពីគណបក្សនយោបាយ ហើយទង្វើនេះ ក៏បង្វែរផងដែរនូវគណនេយ្យភាពរបស់ពួកគាត់ទៅខាងគណបក្សវិញ ។

## ៣. អ្នកមានឥទ្ធិពលធំក្នុងគណបក្ស និងអ្នកមានអំណាចសេដ្ឋកិច្ច កាន់តែអូសទាញនិងបង្កើនឥទ្ធិពលរបស់ខ្លួនទៅលើថ្នាក់ដឹកនាំមូលដ្ឋាន

គណបក្សនយោបាយ ក៏ទទួលបានថវិកាដោយផ្ទាល់ ឬប្រយោលផងដែរ ពីអ្នកដែលមានធនធានច្រើន ។ រឿងនេះបានផ្តល់ឥទ្ធិពលកាន់តែខ្លាំង ដល់អ្នកដែលកំពុងកសាងសិទ្ធិផ្តាច់មុខលើធនធានឃុំ និងអាជីវកម្មរបស់ខ្លួន ។ តាមរយៈទ្រព្យសម្បត្តិ អំណាច និងបណ្តាញរបស់ខ្លួន ពួកគេអាចពង្រឹងសិទ្ធិអំណាច និងបង្កើនឥទ្ធិពលខ្លួន នៅក្នុងការងារនយោបាយ ដើម្បីបំរើផលប្រយោជន៍ផ្ទាល់ខ្លួន និងដើររំលងអាជ្ញាធរមូលដ្ឋានធ្វើឲ្យចុះខ្សោយដល់កិច្ចប្រឹងប្រែងគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់[៣] ក៏ដូចជាដំណើរការធ្វើវិមជ្ឈការទាំងមូល ។ ជនទាំងនោះកាន់តែអូសទាញ និងបង្កើនឥទ្ធិពលរបស់ខ្លួនលើអាជ្ញាធរមូលដ្ឋាន ដោយទៅចូលរួម ឬឲ្យសាច់ញាតិខ្លួនចូលរួមក្នុងការងារនយោបាយថ្នាក់មូលដ្ឋាន ស្រុក ខេត្ត ឬថ្នាក់ជាតិ តាមរយៈការបរិច្ចាគប្រាក់ឲ្យឃុំ ឬការកសាងបណ្តាញជាមួយអ្នកនយោបាយមានអំណាចខ្លាំង ។

ជំនួយទ្រទ្រង់ពីបុគ្គលទាំងនេះ មានសារៈសំខាន់មួយផ្នែកដែរ ព្រោះវាអាចជួយក្រុមប្រឹក្សាឃុំក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍នានា ដែលជាធម្មតាការងារទាំងនោះ ធ្វើមិនកើតបើសិនគ្មានវា ប៉ុន្តែចំណាយតបស្នងសំរាប់ជំនួយទ្រទ្រង់ប្រភេទនេះ ក៏ក្រាស់ក្រែលដែរចំពោះសហគមន៍ ហើយវាអាចបង្ខូចដល់របបប្រជាធិបតេយ្យ និងថ្នាក់ដឹកនាំនៅមូលដ្ឋានថែមទៀត ។

## ៤. អ្នកដឹកនាំចាស់ទុំនិងអាចារ្យ ជាអន្តរការី និងជាអ្នកកៀងគរសំខាន់ បើទោះជាដែនឥទ្ធិពលរបស់ពួកគាត់មានកំរិតតូចនៅឡើយ ហើយពួកគាត់ត្រូវប្រឈមនឹងការអូសទាញពីគណបក្សនយោបាយនានា

អ្នកភូមិសំគាល់ថា ពួកចាស់ទុំក៏ជាថ្នាក់ដឹកនាំដែរ ហើយតែងទៅសុំដំបូន្មានទាក់ទងនឹងសីលធម៌ និងបញ្ហាគ្រួសារ ចំណែកឯថ្នាក់ដឹកនាំនៅមូលដ្ឋាន តែងទៅសុំដំបូន្មានលើបញ្ហាព្រំប្រទល់ភូមិ ឬឃុំ និងការដោះស្រាយទំនាស់ផ្សេងៗ ។ ពួកគាត់ជាអ្នកសម្របសម្រួលរវាងរដ្ឋ និងប្រជាជន ប៉ុន្តែមានឥទ្ធិពលតិចណាស់ ហើយត្រូវប្រឈមមុខនឹងការអូសទាញឲ្យចូលបំរើគណបក្ស និងការងារនយោបាយ ។ ជាក់ស្តែង ចំពោះអាចារ្យដែលជាអ្នកលើកស្ទួយសីលធម៌ខាងសាសនា ក៏កំពុងតែចូលរួមក្នុងការកសាងបណ្តាញនយោបាយដែរ ពីព្រោះវិភាគទានសំរាប់ការអភិវឌ្ឍវត្តអារាមរបស់ពួកគាត់ ភាគច្រើនទទួលបានពីអ្នកនយោបាយ និងអ្នកមានស្តុកស្តម្ភ ដែលជាប់ខ្សែរយៈជាមួយគណបក្សណាមួយ ។ ការអូសទាញក្តោបក្តាប់ថ្នាក់ដឹកនាំទាំងនេះ បានលុបបំបាត់លទ្ធភាពមានសង្គមស៊ីវិលដ៏ខ្លាំងមួយ និងមានអ្នកតំណាង ដែលអាចពាំនាំនូវតម្រូវការរបស់មហាជន ឬអាចកៀងគរកំលាំងមហាជន ។

---

២ ព័ត៌មានលំអិត មានពិភាក្សាផងដែរនៅក្នុង Rusten et al. 2004 ។

៣ មានអ្នកខ្លះជាប់ពាក់ព័ន្ធនឹងការទាញយកធនធាន ។ នៅឃុំមួយមានឧកញ៉ាមួយរូប ធ្វើការជាមួយក្រុមហ៊ុនសម្បទានព្រៃឈើ ហើយបានកាប់ដើមឈើក្នុងទូទាំងឃុំ ។ សកម្មភាពអាជីវកម្មផ្សេងៗទៀតរបស់គាត់ ទទួលបានការយោគយល់ និងដើររំលងអាជ្ញាធរ ព្រោះគាត់បានជួយផ្គត់ផ្គង់ប្អូនគាត់នៅក្នុងការងារនយោបាយមូលដ្ឋាន ។ គាត់ខ្លួនឯង ក៏មានឥទ្ធិពលខ្លាំងដែរទាំងនៅក្នុងមូលដ្ឋាន និងនៅថ្នាក់ជាតិ ។ ប្រជាជនក្នុងឃុំនេះ ពឹងផ្អែកលើព្រៃឈើដើម្បីចិញ្ចឹមជីវិត ហើយការគ្រប់គ្រងធនធានអន់ខ្សោយបែបនេះ ធ្វើឲ្យពួកគេរងទុក្ខលំបាកខ្លាំងនាពេលបច្ចុប្បន្ន ។ ត្រឹមតែប៉ុន្មានឆ្នាំសោះ ព្រៃឈើនៅក្នុងឃុំបានបាត់បង់អស់ ហើយបច្ចុប្បន្នវាបានក្លាយជាដីសម្បទាន ដែលក្នុងនេះ ឧកញ៉ារូបនោះ ទទួលបានដីជាង ១000ហិកតា ។

### ៥. ការដឹកនាំរបស់ NGOs និង CBOs នៅថ្នាក់មូលដ្ឋាន គឺនៅទន់ខ្សោយ

ការសិក្សានេះឃើញថា ការដឹកនាំរបស់អង្គការសង្គមស៊ីវិល ជាពិសេសអង្គការមិនមែនរដ្ឋាភិបាល (NGOs) និងអង្គការមូលដ្ឋានសហគមន៍ (CBOs) គឺនៅទន់ខ្សោយ ។ NGOs ផ្តោតជាចំបងលើការផ្តល់ជំនួយជាសម្ភារៈ ដើម្បីជំរុញសេដ្ឋកិច្ចគ្រួសារ ធ្វើឲ្យជនក្រីក្រអាចប្រើប្រាស់សេវាមូលដ្ឋាន ឬផ្តល់ការបណ្តុះបណ្តាលពីអំពើហិង្សាក្នុងគ្រួសារ ឬបច្ចេកទេសកសិកម្ម ។ NGOs កន្លងមកមិនសូវផ្តោតលើការជួយកសាងវប្បធម៌ពលរដ្ឋល្អ ដែលឲ្យប្រជាពលរដ្ឋយល់ពីតួនាទីរបស់ពួកគាត់ និងបង្កើតវប្បធម៌នៃការចូលរួម ដែលការងារទាំងនោះ តម្រូវឲ្យមានចក្ខុវិស័យ និងការប្តេជ្ញាចិត្តរយៈពេលវែង ក៏ដូចជាកម្មវិធីធ្វើអន្តរកម្មជាប្រព័ន្ធ និងមានការសម្របសម្រួលគ្នា និងការកសាងទំនាក់ទំនងល្អជាមួយអ្នកភូមិ ដោយបង្កើតអ្នកតំណាងដើម្បីជួយសំរួលការងារជាដើម ។ ម៉្យាងទៀត NGOs ដំណើរការដោយប្រើថវិកាពីខាងក្រៅ និងរងឥទ្ធិពលពីកម្មវិធីការងារអ្នកផ្តល់ជំនួយ ជាជាងកម្មវិធីផុសចេញពីតម្រូវការក្នុងមូលដ្ឋាន ដែលមានការចូលរួមច្រើនពីអ្នកភូមិ ។ ដូច្នេះ NGOs មានទិសដៅរយៈពេលខ្លី ដែលកាត់បន្ថយលទ្ធភាពធ្វើជាអ្នកសម្របសម្រួលរវាងរដ្ឋ និងប្រជាជន ។ ករណីសិក្សារបស់យើង បានរកឃើញ CBOs មានតិចតួចណាស់ ហើយវានៅទន់ខ្សោយ គ្មានប្រសិទ្ធភាព និងដំណើរការមិនពេញកំលាំងនៅឡើយ ដោយសារការកង្វះថវិកា ការគាំទ្រ ការចូលរួម អន្តរកម្មជាមួយអាជ្ញាធរសិទ្ធិអំណាច សមត្ថភាព និងទំនុកចិត្ត ។[៤]

### ៦. សន្និដ្ឋាន

នៅក្នុងបរិបទនៃបណ្តាញខ្សែខ្នងខាងនយោបាយ ដែលស្ថាប័ននៅមានលក្ខណៈអន់ខ្សោយនៅឡើយ មានការប្រើប្រាស់របៀបរបបបែបក្រៅផ្លូវការច្រើនជាងបែបផ្លូវការ ។ ថ្នាក់ដឹកនាំមូលដ្ឋានត្រូវជួបប្រទះនឹងស្ថានភាពគណនេយ្យភាពមិនច្បាស់លាស់ ។ បញ្ហាខ្វះសិទ្ធិអំណាចក្នុងការសំរេចចិត្ត និងឯករាជភាពតិចតួចនឹងចោទតទៅទៀត ប្រសិនបើថ្នាក់ដឹកនាំមូលដ្ឋាននៅតែចូលពាក់ព័ន្ធនឹងការងារនយោបាយគណបក្សហួសកំរិត ។ ការពឹងផ្អែកលើការទ្រទ្រង់ និងថវិការបស់គណបក្ស បានប៉ះពាល់ជាខ្លាំងទៅដល់លទ្ធភាពរបស់ថ្នាក់ដឹកនាំ ក្នុងការបំពេញការងារក្នុងតួនាទីរបស់ខ្លួន និងការផ្តល់សេវាផ្សេងៗ ។ ការផ្តល់ការឧបត្ថម្ភទាំងលក្ខណៈជាផ្លូវការ និងក្រៅផ្លូវការរបស់អ្នកមានទ្រព្យធនបែបនេះ ជួយផ្តល់ឱកាសដល់ពួកគេឲ្យមានឥទ្ធិពលទៅលើផែនការអភិវឌ្ឍន៍ ដើម្បីទាញយកផលចំណេញសំរាប់អាជីវកម្មរបស់ពួកគេ ។ ជាងនេះទៀត ការអូសទាញអ្នកដឹកនាំក្រៅផ្លូវការដែលមានប្រជាប្រិយភាពទាំងឡាយ ផ្តល់ឱកាសល្អសំរាប់ការភ្ជាប់ទំនាក់ទំនងរវាងប្រជាជន និងរដ្ឋខ្លះដែរ ប៉ុន្តែភាគច្រើនទង្វើនេះបានបំរើផលប្រយោជន៍នៃការពង្រឹងអំណាច និងឥទ្ធិពលរបស់គណបក្សទៅវិញ ។ សង្គមស៊ីវិលជាតួអង្គមួយ សំខាន់បំផុត (ឬជាតួអង្គចំបងគេ) ក្នុងការភ្ជាប់ទំនាក់ទំនងរវាងរដ្ឋ និងសង្គម ប៉ុន្តែដោយសារអង្គការសង្គមស៊ីវិល ដំណើរការតាមចក្ខុវិស័យរយៈពេលខ្លី ដូច្នេះ ពួកគេមិនអាចចាត់ទុកជាថ្នាក់ដឹកនាំដែលអាចតំណាង ឬជួយអ្នកភូមិបានឡើយ ។ នេះជារឿងគួរឲ្យខកចិត្តសម្រាប់របបប្រជាធិបតេយ្យ ព្រោះវាមានន័យថា វប្បធម៌នៃការចូលរួមរបស់ប្រជាពលរដ្ឋនៅមិនទាន់កសាងបាននៅឡើយ ។

## គោលនយោបាយពាក់ព័ន្ធ

### ១. កែលំអវិន័យផ្ទៃក្នុងគណបក្ស និងបើកចំហឱកាសសំរាប់បេក្ខជនថ្មីៗ

ការរកឃើញថាអ្នកដឹកនាំច្រើនតែមុខដដែលៗ បញ្ជាក់ឲ្យឃើញថា ទាំងប្រជាជនទាំងគណបក្ស នៅតែមានទំនោរទៅលើអ្នកដឹកនាំដែលមានលក្ខណៈប្រជាប្រិយតាមបែបប្រពៃណី ។ តែទោះជាយ៉ាងនេះក្តី ការសិក្សាក៏បានរកឃើញថា ប្រជាជនក៏កំពុងតែមានការយល់ដឹង និងក្លាហានជាងមុន ក្នុងការបោះឆ្នោតទំលាក់ថ្នាក់ដឹកនាំសព្វថ្ងៃ ប្រសិនបើពួកគេទទួលរងអំពើអយុត្តិធម៌ ឬការកេងប្រវ័ញ្ច ។ ប៉ុន្តែពួកគេអាចធ្វើដូច្នេះបានលុះត្រាតែមានជំរើសបេក្ខជនថ្មីដែលល្អជាង ។ ដូច្នេះ គណបក្សនយោបាយគួរស្វែងរក និងសុខចិត្តទទួលយកបុគ្គលក្មេងៗមានសមត្ថភាពល្អ ដែលអាចបំរើប្រជាជន និងអនុវត្តមុខងាររបស់ខ្លួនបាន ។ ដើម្បីធ្វើយ៉ាងនោះបាន គឺគួរមានវិន័យផ្ទៃក្នុងគណបក្សមួយ សំរាប់ដាក់ទណ្ឌកម្មលើសមាជិកណាដែលប្រព្រឹត្តខុសក្នុងពេលបំពេញមុខងារ និងផ្តល់រង្វាន់ដល់អ្នកអនុវត្តការងារបានល្អ ជួយលើកតម្កើងការងារ ភាពពេញសិទ្ធិ និងកេរ្តិ៍ឈ្មោះរបស់គណបក្ស ។

ក្នុងការជ្រើសរើសបេក្ខជនរបស់ខ្លួន គណបក្សនយោបាយ គួរផ្តល់អាទិភាពលើគុណសម្បត្តិ និងលទ្ធផលការងារកន្លងមក ជាបន្ថែមពីលើប្រជាប្រិយភាព និងសមត្ថភាព ។ ការអូសទាញបុគ្គលដែលល្បីល្បាញ និងមានប្រជាប្រិយភាពស្រាប់ក្នុងចំណោមប្រជាជន ដោយកុំឲ្យបុគ្គលនោះទៅចូលរួមក្នុងគណបក្សដទៃទៀត ហើយដែលបុគ្គលនោះ អាចនឹងមិនមានចំណាប់អារម្មណ៍ក្នុងការបំរើប្រជាជនក្នុងភូមិ ឃុំ និងរដ្ឋនោះវាមិនមែនជាដំណោះស្រាយឈ្នះ-ឈ្នះឡើយ ។ គណបក្សនានា ជាពិសេសគណបក្សកាន់អំណាច គួរមានសុឆន្ទៈនយោបាយក្នុងការបើកទ្វារចំហដល់បេក្ខជនថ្មីៗ និងការផ្តល់បេក្ខជនច្រើននាក់ជាងមុន ឲ្យអ្នកភូមិធ្វើការជ្រើសរើស ។

### ២. កែលំអគណនេយ្យភាពរបស់ក្រុមប្រឹក្សាឃុំ តាមរយៈស្វ័យភាពហិរញ្ញវត្ថុ និងកំណើនមូលនិធិ

ច្បាប់ស្តីពីរដ្ឋបាលឃុំ សង្កាត់ ចែងថា ឃុំអាចយកពន្ធ និងមានសិទ្ធិរកចំណូលពីប្រភពផ្សេងៗទៀត ប៉ុន្តែច្បាប់អង្គការចែងថា

---

៤ ព័ត៌មានលំអិតមាននៅក្នុងឯកសារពិគ្រោះលេខ ៣៥ របស់ វបសអ ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☏ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨
🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@wicam.com.kh
website: http://www.cdri.org.kh

ពន្ធប្រមូលយកដោយថ្នាក់ក្រោមជាតិ គួរបង្កើតឡើងក្រោមច្បាប់មួយ ដែលបច្ចុប្បន្នមិនទាន់អនុម័តចេញនៅឡើយទេ ។ ក្រៅពីច្បាប់នេះ ថ្នាក់ដឹកនាំរដ្ឋបាលមូលដ្ឋាន ត្រូវការនូវការគាំទ្រ និងការជួយណែនាំក្នុងការប្រមូលពន្ធនៅមូលដ្ឋាន ។

កំណើនធនធានហិរញ្ញវត្ថុឃុំ នឹងបង្កើនប្រសិទ្ធភាព និងឆន្ទៈឃុំ ក្នុងការឆ្លើយតប និងបង្ហាញគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ។ ជាក់ស្តែង កាលណាថ្នាក់ដឹកនាំនៅមូលដ្ឋានអាចដាក់អនុវត្តការប្រមូលពន្ធ ពេលនោះគោលគំនិតនៃកិច្ចសន្យាឆ្លើយតបពីសំណាក់រដ្ឋាភិបាលទៅប្រជាជន គឺអាចកសាងឡើងជាបណ្តើរៗបាន ហើយថ្នាក់ដឹកនាំនៅមូលដ្ឋាន ក៏នឹងមានអំណាចច្រើនជាងមុន ក្នុងការគ្រប់គ្រងធនធានធម្មជាតិ ។

### ៣. ការបង្កើនស្វ័យភាព និងឯករាជភាពនៃក្រុមប្រឹក្សាឃុំ នឹងអាចជួយកាត់បន្ថយនូវការងារនយោបាយគណបក្សក្នុងឃុំ និងការអូសទាញអ្នកដឹកនាំខាងសាសនា ឲ្យក្លាយជាអ្នកជំនួយខាងនយោបាយ

ការអនុវត្តច្បាប់អង្គការ និងការបង្កើនឆន្ទៈនយោបាយក្នុងការផ្ទេរសិទ្ធិអំណាច និងសិទ្ធិសំរេចពេញលេញទៅឲ្យឃុំ គួបផ្សំនឹងកំណើនស្វ័យភាពហិរញ្ញវត្ថុនៃក្រុមប្រឹក្សាឃុំ នឹងជួយដល់ក្រុមប្រឹក្សាឃុំក្នុងការដោះស្រាយបញ្ហាសំខាន់ៗ ដូចជាការគ្រប់គ្រងធនធានធម្មជាតិ និងការការពារធនធានធម្មជាតិពីការធ្វើអាជីវកម្មផ្តាច់មុខជាដើម ។ វាក៏ជួយកាត់បន្ថយការពឹងផ្អែករបស់គណបក្សនយោបាយ និងអាជ្ញាធរមូលដ្ឋានទៅលើជំនួយហិរញ្ញវត្ថុក្រៅផ្លូវការពីអ្នកមានទ្រព្យធន ដែលតែងព្យាយាមអូសទាញក្តោបក្តាប់ថ្នាក់ដឹកនាំនៅមូលដ្ឋាន ។

ជាងនេះទៅទៀត ការអូសទាញផ្នែកនយោបាយទៅលើអ្នកដឹកនាំ និងស្ថាប័នខាងសាសនា ក៏អាចកាត់បន្ថយបានដែរ ។ ទោះជាយ៉ាងនេះក្តី ការសិក្សាបានរកឃើញថា វត្តអារាមនៅមូលដ្ឋានរងឥទ្ធិពលពីអ្នកមានឥទ្ធិពលក្នុងគណបក្ស ឬអ្នកនយោបាយ និងអ្នកមានស្តុកស្តម្ភនៅក្នុងមូលដ្ឋាន ។ ជួនកាលវត្តអារាម បានផាត់ចេញនូវប្រជាពលរដ្ឋណាដែលគាំទ្រគណបក្សផ្សេង ហើយរឿងនេះ បានជះឥទ្ធិពលលើឥរិយាបថ និងចំណាប់អារម្មណ៍របស់ប្រជាជនចំពោះវត្តអារាម ។ អារម្មណ៍ដែលត្រូវគេផាត់ចេញពីបុណ្យទានខាងសាសនា និងកិច្ចការសង្គមផ្សេងៗទៀតនៅក្នុងភូមិ ធ្វើឲ្យអ្នកភូមិមានការអាក់អន់ចិត្តនឹងវត្ត ។ ដំណោះស្រាយក្នុងករណីនេះ គឺស្ថិតលើឆន្ទៈនយោបាយ និងវិន័យគណបក្ស ដើម្បីស្វែងរកភាពពេញសិទ្ធិពិតប្រាកដតាមរយៈមធ្យោបាយតាមបែបប្រជាធិបតេយ្យ ជាជាងការព្យាយាមអូសទាញក្តោបក្តាប់ស្ថាប័នផ្សេងៗនៅក្នុងមូលដ្ឋាន ។

### ៤. ត្រូវសម្របសម្រួល និងបង្កើតកិច្ចសហប្រតិបត្តិការរវាងអង្គការមិនមែនរដ្ឋាភិបាល (NGOs) អង្គការមូលដ្ឋានសហគមន៍ (CBOs) និងអាជ្ញាធរមូលដ្ឋាន

កត្តាដែលអាចសំខាន់ជាងគេ ក្នុងការកសាងរបបប្រជាធិបតេយ្យ គឺតួនាទីនៃសង្គមស៊ីវិលដ៏រឹងមាំ ។ ការសិក្សារបស់យើងបានបញ្ជាក់គាំទ្រលើទស្សនៈនៃឯកសារយោងជាច្រើន ដែលថាសង្គមស៊ីវិលនៅកម្ពុជានៅទន់ខ្សោយនៅឡើយ ។ កម្ពុជាត្រូវមានការសម្របសម្រួលកាន់តែច្រើន និងកាន់តែប្រសើររវាងសង្គមស៊ីវិល និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីកាត់បន្ថយការត្រួតការងារគ្នា និងភាពមិនចុះសម្រុងនឹងគ្នា និងបង្កើនសេវាកម្មឲ្យចំតម្រូវការ ។ អង្គការសង្គមស៊ីវិល ត្រូវចូលពាក់ព័ន្ធកាន់តែច្រើនជាមួយមូលដ្ឋាន ទាំងក្នុងលក្ខន្តិកៈ និងក្នុងដំណើរការ ហើយគម្រោងនានា ក៏ត្រូវមានលក្ខណៈជាប្រព័ន្ធប្រសើរជាងមុន ដោយមានការផ្តោតកាន់តែច្រើន លើការកសាងអ្នកតំណាងរបស់ប្រជាជនមូលដ្ឋាន និងការជួយឲ្យមានរយៈពេលវែង ។ អង្គការដែលមានគោលដៅធ្វើជាតំណាងឲ្យប្រជាជន ដូចជា CBOs ជាដើម សព្វថ្ងៃមិនមានដំណើរការជាក់ស្តែងទេ ដោយសារកង្វះអំណាច សិទ្ធិតាមផ្លូវច្បាប់ និងការគាំទ្រ ។ ដូច្នេះ ពួកគេត្រូវមានជាសំខាន់នូវការគាំទ្រធំទូលាយជាងមុន និងការបញ្ជាក់ឲ្យច្បាស់លាស់រវាងតួនាទីរបស់ពួកគេ និងតួនាទីរបស់ក្រុមប្រឹក្សាឃុំ ដើម្បីពង្រឹងកិច្ចការពារធនធានរបស់ឃុំ និងប្រយោជន៍របស់អ្នកភូមិ ។

## ឯកសារយោង

Kim Sedara & Joakim Öjendal (2007), *Where Decentralisation Meets Democracy: Civil Society, Local Government and Accountability in Cambodia*, Working Paper 35 (Phnom Penh: CDRI)

Rusten, Caroline, Kim Sedara, Eng Netra & Pak Kimchoeun (2004), *The Challenges of Decentralisation Design in Cambodia* (Phnom Penh: CDRI)

Thon, Vimealea, Ou Sivhuoch, Eng Netra & Ly Tem (2009), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces*, Working Paper 42 (Phnom Penh: CDRI)